# ៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

## ប្រកាសលេខ ៣០៧៨ សក.ជជ.កពយ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៤

## ស្តីពីបែបបទផ្ទេរកម្មសិទ្ធិយានយន្ត ឬ ជលយានយន្ត និង ការ បន្តពេលប្រើប្រាស់បណ្ណសំគាល់យានយន្ត ពាក់ផ្លាកលេខ " AT "

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណៈការ និង ដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ចរាចរផ្លូវគោក ដែលបានដាក់ជាធរមាន ចាប់ពីថ្ងៃ ១៧ សីហា ១៩៩១
- បានឃើញប្រកាសលេខ ០៥៤ សចក.ប្រក ចុះថ្ងៃទី ២០ ធ្នូ ១៩៩៤ ស្តីពីការផ្លាស់ប្តូរផ្លាកលេខ និងលេខយាន យន្តសាជាថ្មី
- តាមសេចក្តីត្រូវការចាំបាច់របស់ប្រទេសជាតិ ដែលឈានទៅរកការរីកចំរើន

### សំរេច

### ក. បែបបទផ្ទេរកម្មសិទ្ធិយានយន្ត ឬ ជលយានយន្ត

**ប្រការ ១ :** នៅពេលលក់យាយន្ត ឬ ជលយានយន្តរបស់ខ្លួន ម្ចាស់កម្មសិទ្ធិត្រូវធ្វើសេចក្តីប្រកាសលក់យានយន្ត ឬ ជលយាន យន្ត ( La déclaration de la vente ) ដោយមានបញ្ជាក់ឈ្មោះ មុខរបរ អាសយដ្ឋានរបស់អ្នកទិញអោយបានច្បាស់លាស់ ។ សេចក្តីប្រកាសលក់នេះត្រូវមានរដ្ឋអំណាច ស្រុក ខ័ណ្ឌ ដឹងឮ និង ទទួលស្គាល់ ។

**ប្រការ ២ :** អ្នកទិញត្រូវដាក់ពាក្យសុំផ្ទេរកម្មសិទ្ធិ ដោយមានសេចក្តីប្រកាសលក់ភ្ជាប់ជាមួយ នៅ :

- អគ្គនាយកដ្ឋានដឹកជញ្ជូន : ចំពោះអ្នកទិញណាដែលមានអាស័យដ្ឋាននៅរាជធានីភ្នំពេញ និង ខេត្តកណ្តាល
- នៅតាមមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត - ក្រុង :
  ចំពោះអ្នកទិញដែលមានអាស័យដ្ឋាននៅតាមបណ្តា ខេត្ត ក្រុង

**ប្រការ ៣ :** ការផ្ទេរកម្មសិទ្ធិពីខេត្ត-ក្រុងទៅខេត្តមួយទៀត ត្រូវមានសេចក្តីបញ្ជាក់ដឹងឮរបស់មន្ទីរសាធារណការ និង ដឹកជញ្ជូនរបស់អ្នកលក់នៅលើសេចក្តីប្រកាសលក់ ។

**ប្រការ ៤ :** ការផ្ទេរកម្មសិទ្ធិយានយន្ត ឬ ជលយានយន្ត ត្រូវធ្វើអោយហើយស្រេចក្នុងរយៈពេល ៧ ថ្ងៃ គិតចាប់តាំងពីថ្ងៃធ្វើសេចក្តីប្រកាសលក់ ។

## ខ. ការបន្តរយៈពេលប្រើប្រាស់ បណ្ណសំគាល់យានយន្ត " AT "

**ប្រការ ៥ :** គ្រប់ម្ចាស់យានយន្តដែលមានពាក់ផ្លាកលេខ " AT " ត្រូវធ្វើពាក្យសុំបន្តរយៈពេល ប្រើប្រាស់ប័ណ្ណសំគាល់យានយន្ត និង ប្តូរផ្លាកលេខថ្មី អោយបានមុនផុតរយៈពេលប្រើប្រាស់ដែលមានកំណត់នៅលើប័ណ្ណសំគាល់យានយន្ត ។

**ប្រការ ៦ :** ក្នុងករណីមិនគោរពតាមប្រកាសនេះទេ ម្ចាស់យានយន្ត ឬ ជលយានយន្ត ត្រូវទទួលនូវការពិន័យជាប្រាក់ដែលកំណត់ដោយក្រសួងសាធារណការ និង ដឹកជញ្ជូន ទៅតាមករណីវៀង ១ ខួប គិតចាប់ តាំងពីថ្ងៃផុតរយៈពេលប្រើប្រាស់ ។

**ប្រការ ៧ :** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨ :** លោកអគ្គនាយក, នាយកខុទ្ទកាល័យ លោកប្រធានការិយាល័យយានយន្ត នៃអគ្គនាយកដ្ឋានដឹកជញ្ជូន លោកប្រធាន មន្ទីរសាធារណការ និង ដឹកជញ្ជូនគ្រប់ខេត្ត-ក្រុង ត្រូវអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់តាមខ្លឹមសារនៃប្រកាសនេះ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

ហត្ថលេខា និង ត្រា

**អ៊ឹង គៀត**